# ប្រជុំរឿងផ្សេងៗ

ភាគទី១

## កាតញ្ញូ ជាធម៌អ្នកប្រាជ្ញ





ដោយ ភិក្ខុៈ ធម្មសិរី សែម ចន្ទធីរ៍

មណ្ឌលវប្បធម៌ខ្មែរនៅស៊ីស

ព.ស. ២៥៥៥

# អារម្ភកថា

អត្ថបទ ប្រជុំរឿងផ្សេងៗ ដែលស្ថិតនៅក្នុងហត្ថាទាំងទ្វេរបស់ លោកអ្នកនេះ គឺជាកម្រងរឿងព្រេងផ្សេងៗ ដែលមានពិតក្នុងព្រះពុទ្ធសាសនាបានឆ្លុះបញ្ចាំងពីនិន្នាការផ្សេងៗក្នុងសង្គមសម័យនោះ ហើយដែលនៅតែត្រឹមត្រូវនឹងព្រឹត្តិការណ៍នានា នាសម័យបច្ចុប្បន្នផងដែរ។

អត្ថបទទាំងនេះ ខ្ញុំសូមចែកជាភាគតូចៗ មានពី ៣០ ទៅ ៥០ ទំព័រ មិនឲ្យច្រើនពេកនោះឡើយ។ ក្នុងភាគនីមួយៗ មានពី៣ ទៅ ៥ រឿង តាមដែលរឿងនោះវែងឬខ្លី ដូចជាភាគទី ១ នេះ ខ្ញុំលើកយករឿងចំនួន៣ ដែលនិយាយបរិយាយអំពីការចិញ្ចឹមម្តាយឪពុក ហើយឲ្យ ឈ្មោះថា **កតញ្ញូ ជាធម៌អ្នកប្រាជ្ញ** រីឯភាគផ្សេងៗទៀត នឹង មានចំណុចផ្សេងៗ ពីនេះ។

ខ្ញុំសង្ឃឹមថា អត្ថបទទាំងនេះ នឹងជួយលោកអ្នកឲ្យបានយល់ពី ផលនៃការបីបាច់រក្សាអ្នកមានគុណទាំងពីរ ដែលលោកជាព្រះរស់ នៅក្នុងផ្ទះរបស់ខ្លួន។ ទាំងជួយសម្រាលភាពតានតឹងពីការងារ នៅពេល បានអានអត្ថបទទាំងនេះ ១៥នាទីមុនពេលចូលទៅសម្រាកសម្រាន្ត។

ខ្ញុំរីករាយបំផុតក្នុងការជួយកែតម្រូវរបស់លោកអ្នកវិញ្ញូជនទាំងពួង។ ខ្ញុំសូមឧទ្ទិសអត្ថបទរឿងទាំងនេះជូនបុព្វការីជនទាំងឡាយ។ ម្យ៉ាងសូម អ្នកអានទាំងឡាយបានចំណែកនៃបញ្ញានេះគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិការឿង

រឿង ស្រែស្រូវសាលី ..................................................................... ០៣

រឿង ភិក្ខុចិញ្ចឹមម្ដាយ ..................................................................... ១៨

រឿង ដំរីចិញ្ចឹមម្ដាយ ..................................................................... ៣១

# រឿងស្រែស្រូវសាលី[១]

សត្ថា: ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនឹងភិក្ខុមួយអង្គដែលចិញ្ចឹមម្តាយ ទើបទ្រង់សម្តែងនូវរឿងនេះឡើងដោយមានពាក្យខាងដើមថា *ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ* ដូច្នេះជាដើម ។ រឿងភិក្ខុដែលចិញ្ចឹមម្តាយនេះ មានសម្តែងនៅក្នុងរឿង ព្រះសុវណ្ណសាម[២]។ លំដាប់នោះ ព្រះបរមគ្រូបានត្រាស់ហៅភិក្ខុនោះ មកសួរថា៖

ម្នាលភិក្ខុ! ឮថា អ្នកឯងចិញ្ចឹមគ្រហស្ថពិតមែនឬ?

ភិក្ខុអង្គនោះ ក៏ទូលពុទ្ធដីកាថា៖

បពិត្រព្រះអង្គដ៏ចម្រើន ការណ៏នុ៎ះ ពិតមែន ព្រះអង្គ!

តើអ្នកនោះ ត្រូវជាអ្វីនឹងអ្នកដែរ?

បពិត្រព្រះអង្គចម្រើន ពួកគាត់ត្រូវជាមាតាបិតារបស់ខ្ញុំព្រះអង្គ!

ឱ! ល្អហើយភិក្ខុ! (អ្នកធ្វើនេះត្រឹមត្រូវហើយ) ពួកអ្នកប្រាជ្ញទាំងឡាយ ពីបុរាណ សូម្បីកើតក្នុងកំណើតសត្វសេកជាសត្វតិរច្ឆាន ក៏ធ្លាប់បានត្រាច់គោចរ

---

[១]សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក នវមភាគ ៦០ ទំព័រ ១

[២]រឿងព្រះសុវណ្ណសាម មានមកក្នុងទសជាតក៏ហើយ មិនបាននាំមកក្នុងទីនេះទេ។

ស្វែងរកអាហារចំណីពាំនឹងចំពុះមកចិញ្ចឹមមាតាបិតាដែលចាស់ជរា ដេកនៅក្នុងសំបុកដែរ ទើបទ្រង់លើករឿងអតីតនិទានមកសម្តែង ប្រាប់ដូច្នេះថា៖

កាលពីព្រេងនាយ មានព្រះរាជាមួយព្រះអង្គព្រះនាម **មគធរាជ** សោយរាជ្យក្នុងក្រុងរាជគ្រឹះ ។ ស្ថិតនៅភាគឦសាន្តនៃក្រុងនេះ មាន ព្រាហ្មណគ្រាមមួយឈ្មោះសាលិន្ទិយៈ ដែលស្ថិតនៅក្នុងអាណាខេត្រ របស់ដែនមគធៈនោះ។ ក្នុងចំណោមអ្នកភូមិសាលិន្ទិយៈទាំងនោះ មានព្រាហ្មណ៍ម្នាក់ ឈ្មោះ **កោសិយគោត្រ** មានដីស្រែ ៤០០ហិចតា សម្រាប់ដាំស្រូវសាលី។ នៅពេលដែលសន្ទូងលាស់ល្អ គាត់ក៏ឲ្យគេធ្វើ របងព័ទ្ធយ៉ាងមាំ ហើយចែកឲ្យអ្នកបម្រើរបស់គាត់ចំនួន ២០០ ហិចតា ដោយឲ្យម្នាក់មើលថែរក្សា ២០ ហិចតា, ម្នាក់ ២៥ ហិចតា ជាដើម និង ២០០ ហិចតាទៀត គាត់ជួលឲ្យកូនឈ្នួលម្នាក់ មើលថែដើម្បីកាត់បំណុល។ បុរសអ្នកស៊ីឈ្នួលនោះ ក៏ធ្វើខ្ទមនៅចាំទាំងយប់ទាំងថ្ងៃ។

នៅនាជ្រលងភ្នំមួយ ភាគឦសាន្តនៃស្រែនោះ មានព្រៃរកាយ៉ាងធំ មានសត្វសេកជាច្រើនអាស្រ័យនៅ។ សម័យនោះឯង ព្រះពោធិសត្វ បានកើតជាកូនស្តេចសេកក្នុងហ្វូងនោះ។ នៅពេលមានវ័យចម្រើនឡើង មានរូបឆោមលោមពណ៌ស្អាតក្រៃលែង មានកម្លាំងខ្លាំង និងមានខ្លួនប៉ុនដុំរទេះ។ បន្ទាប់មកបិតាដែលមានវ័យចាស់ហើយ ក៏ ប្រគល់ឲ្យព្រះពោធិសត្វគ្រប់គ្រងហ្វូងសេកនោះថា "ឥឡូវនេះ ខ្លួនអញចាស់ហើយ មិនអាចទៅណាឆ្ងាយបានទេ ចូរបា! គ្រប់គ្រងរក្សា នូវហ្វូងសេកទាំងនេះផងចុះ!" ។

ចាប់តាំងពីព្រឹកស្អែកនោះទៅ ព្រះពោធិសត្វមិនឲ្យមាតាបិតាហើរ ទៅរកចំណីទៀតទេ ព្រះអង្គនាំសេកជាបរិវារទៅកាន់ព្រៃហេមពាន្ត បរិភោគស្រូវសាលីដែលដុះឯង ដរាបដល់ឆ្អែត ហើយពាំស្រូវសាលី នឹងចំពុះត្រឡប់មកជូនមាតាបិតាបរិភោគផង។

ថ្ងៃមួយ ពួកសេកក៏សួរស្តេចសេកពោធិសត្វថា ពីមុនមានគេប្រាប់ថា ក្នុងដែនមគធៈមានស្រូវសាលីដុះនៅខែនេះឯង តើឥឡូវ ដុះហើយ ឬនៅហ្ន៎? ស្តេចសេកតបថា បើដូច្នោះមានតែទៅមើលទើបបានដឹង ហើយក៏បញ្ជូនសេកពីរក្បាលទៅ។ សេកទាំងពីរបានហើរទៅចុះក្នុងដែនមគធៈ ចឹកស៊ីស្រូវសាលី ត្រង់ស្រែរបស់បុរសស៊ីឈ្នួលរក្សានោះ ហើយពាំស្រូវមួយកួរ មកកាន់ព្រៃរការិញ ដាក់ជិតជើងស្តេចសេក ទូលថា ក្នុងស្រែឯណោះ មានស្រូវយ៉ាងនេះមែន។

ព្រឹកឡើង ស្តេចសេកពោធិសត្វហែហមដោយសេកជាបរិវារ ហើរទៅចុះក្នុងស្រែនៃអ្នកស៊ីឈ្នួលនោះ។ បុរសនោះ កាលបើឃើញ ហ្វូងសេក ចុះស៊ីស្រូវសាលីយ៉ាងនេះ ក៏រត់ទៅដេញបង្អើលពីនោះផង ពីនេះផង តែក៏នៅតែមិនឈ្នះ។ ពួកសេកទាំងឡាយជាបរិវារស៊ីស្រូវឆ្អែតហើយក៏ហើរទៅទាំងក្អាកក្អាយ ប្លែកតែស្តេចសេកមានបរិវារជាច្រើនហែហម ប្រមូលពាំយកកួរស្រូវជាច្រើនទៅឲ្យមាតាបិតា។

ចាប់តាំងពីថ្ងៃនោះមក សេកអម្បាលនោះក៏ចុះស៊ីស្រូវតែក្នុងស្រែ នោះរហូត ឃើញដូច្នោះ បុរសនោះក៏គិតថា បើសិនជាសត្វសេកទាំងនេះ ស៊ីតែយ៉ាងនេះពីរបីថ្ងៃទៀត វានឹងគ្មានសល់អ្វីទេ ព្រាហ្មណ៍នឹង តម្លើងថ្លៃបំណុលស្រូវអញជាមិនខាន ចឹង! មានតែអញទៅប្រាប់គាត់ទើបបាន! ហើយក៏ប្រមូលលីកណ្ដាប់ស្រូវ និងបណ្ណាការខ្លះសំដៅទៅសាលិន្ទិយគ្រាម ដើម្បីជួបព្រាហ្មណ៍។ លុះអ្នកកម្លោះទៅដល់ហើយ ក៏គោរពសំពះសួរព្រាហ្មណ៍ ជូននូវអំណោយ ហើយឈរមួយកន្លែង។ នៅពេលដែលព្រាហ្មណ៍សួរថា ម៉េចទៅ! អ្នកកម្លោះ! ស្រូវក្នុងស្រែ បានផលល្អទេ? ក៏ឆ្លើយតបថា បាទ!ទានព្រោស! ល្អដែរ! រួចក៏ពោល ពីរគាថាទៀតថា៖

បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែបរិបូណ៌ដែរ តែពួកសេកតែងស៊ី បពិត្រព្រាហ្មណ៍! ខ្ញុំសូមជំរាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំង អស់នោះបានឡើយ! បណ្ដាសេកទាំងនោះ មានសេកមួយដែលល្អដោយចំណែកទាំងពួងជាងសេកទាំងនោះ (សេកនោះមានរូបល្អ មានចំពុះក្រហម មានភ្នែកដូចផ្លែទំពាំងបាយជូរ មានជើងក្រហម មានក លំអដោយស្នាមក្រហមបីជុំ មានប្រមាណស្មើដោយមយូរាជ៏អស្ចារ្យ) ស៊ីនូវស្រូវសាលីតាមសេចក្ដីប្រាថ្នា រួចហើយ ក៏ពាំស្រូវដោយចំពុះហើរទៅទៀត។

ព្រាហ្មណ៍បន្ទាប់ពីបានស្ដាប់ពាក្យអ្នករក្សាស្រែនោះហើយ មានចិត្តស្រឡាញ់ស្ដេចសេកពន់ពេក ក៏សួរអ្នករក្សាស្រែថា នែ! អ្នកកម្លោះ! តើឯង!

ចេះដាក់អន្ទាក់ទេ? បុរសនោះឆ្លើយថា បាទ! ចេះ! ពេលនោះ គាត់ក៏បង្គាប់ ថា ជនទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសត្វ បក្សីនោះនឹងជាប់ ចូរអ្នកចាប់វាទាំងរស់ នាំមកក្នុងសំណាក់នៃអញ។

នាយរក្សាស្រែត្រឡប់ទៅវិញ ទាំងមានចិត្តត្រេកអរពន់ពេកណាស់ ដោយព្រាហ្មណ៍មិនបានតម្លើងថ្លៃបំណុលស្រូវ ។ គាត់បានវេញកន្ទុយ សេះធ្វើជាអន្ទាក់ រួចទៅសង្កេតចាំមើលកន្លែងដែលស្តេចសេកចុះជាប្រក្រតី ក៏ដឹងថាថ្ងៃនេះ ស្តេចសេកចុះត្រង់នេះ។ ស្អែកឡើង គាត់ ក្រោកពីព្រលឹមយកអន្ទាក់ទៅដាក់ រួចធ្វើទ្រុងប៉ុនក្អមទឹក អង្គុយក្នុងខ្ទម ចាំមើលហ្វូងសេកហើរចុះមក។ ស្តេចសេកមិនមែនជាសត្វលោភលន់ទេ បាននាំហ្វូងសេកមក ក៏ចុះត្រង់កន្លែងដែលខ្លួនបរិភោគពីម្សិលមិញដដែល ហេតុនោះហើយ បានជាជើងជាប់អន្ទាក់ពេលនោះ។ ស្តេចសេកដឹងខ្លួនថា ជើងរឹតជាប់ដោយអន្ទាក់ហើយ ក៏គិតថា បើអាត្មាអញស្រែកឥឡូវថា អញជាប់អន្ទាក់ហើយ ពួកញាតិរបស់អញនឹងភ័យខ្លាច ហើរចេញទៅទាំងស៊ីចំណីមិនទាន់ឆ្អែត ដូច្នេះ អញត្រូវតែអត់ទ្រាំ រហូតដល់ពួកគេស៊ីឆ្អែតសិន។ (នៅពេល) ដែលស្តេចសេកដឹងថា សេកទាំងអស់ស៊ីឆ្អែតហើយ និងដោយភ័យខ្លាចថាខ្លួននឹងស្លាប់ផងនុ៎ះ ក៏ស្រែកយ៉ាងខ្លាំងបីដង ពួកហ្វូងសេកក៏ហើរទៅអស់ នៅតែស្តេចសេកម្នាក់ឯង ថ្លែងវិយោគថា បក្សីជាញាតិរបស់អញទាំងនុ៎ះ សូម្បីម្នាក់ ក៏គ្មានត្រឡប់ងាកមើលអញឡើយ តើអាត្មាអញបានធ្វើបាបកម្មអ្វីទៅ ? រួចក៏ពោលគាថានេះថា៖

បក្សីទាំងនុ៎ះ ស៊ីផង ផឹកផង ហើយហើរចេញទៅ

អាត្មាអញម្នាក់ឯង ជាប់អន្ទាក់ហើយ អាត្មាអញ

ធ្វើហើយ នូវអំពើលាមកដូចម្តេច ?

នាយរក្សាស្រែ បានឮសម្រែកស្តេចសេក និងសន្ធឹកទទះស្លាបនៃ សេកដទៃទៀតដែលហើរទៅឰដ៏អាកាស ឆ្ងល់ថា អ្វីហ្នឹ? រួចក៏ចុះពីខ្ទម ដើរតម្រង់ទៅទីដាក់អន្ទាក់ ឃើញស្តេចសេកជាប់អន្ទាក់ដែលខ្លួនបាន ដាក់ហើយយ៉ាងនេះ ក៏មានចិត្តរីករាយ ដោះស្តេចសេកចេញពីអន្ទាក់ ចងជើងទាំងពីរយ៉ាងមាំនាំយកទៅជូនព្រាហ្មណ៍នៅសាលិន្ទិយគ្រាម។

ព្រាហ្មណ៍ដែលមានចិត្តស្រឡាញ់មហាសត្វជាខ្លាំង ទទួលចាប់យ៉ាង មាំដោយដៃទាំងពីរមកដាក់ឲ្យឈរលើស្មា ហើយពោលពីរគាថាទៅ កាន់ស្តេចសេកដោយរីករាយថា៖

ឧទរំ នូន អញ្ញេសំ សុវ អច្ចោទរំ តាវ

ភុត្វា សាលឹ យថាកាមំ តុណ្ឌេនាទាយ គច្ឆតិ ។

ម្នាលសេក ពោះសេកទាំងឡាយដទៃ (ជាពោះតូចល្មម) ដោយពិត (ចំណែកខាងពោះ) របស់អ្នក ជាពោះធំជ្រុលពេក បានជាអ្នកស៊ីស្រូវ សាលីតាមសេចក្តីប្រាថ្នារួចហើយក៏ពាំយកស្រូវដោយចំពុះហើរទៅ។

កោដ្ឋំ នុ តត្ថ បូរេសិ សុរំ វេរំ នុ តេ មយា

បុដ្ឋោ មេ សម្ម អក្ខាហិ កុហឹ សាលឹ និធេយ្យសិ ។

ម្នាលសេក អ្នកបំពេញជង្រុកក្នុងព្រៃរកានោះឬ ឬក៏អ្នកចងពៀរនឹងយើង? ម្នាលសំឡាញ់ យើងសួរហើយ អ្នកចូរប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា?

បន្ទាប់ពីបានស្តាប់សំណួរហើយ ស្តេចសេកក៏ពោលគាថា ៧បទ ជាភាសាមនុស្សដ៏ពីរោះយ៉ាងនេះថា៖

ន មេ វេរំ តយា សទ្ធឹ កោដ្ឋំ មយ្ហំ ន វិជ្ជតិ

ឥណំ មុញ្ចាមិណំ ទម្មិ សម្បត្តោ កោដសិម្ពលឹ

និធឹបិ តត្ថ និទហាមិ ឯវំ ជានាហិ កោសិយ ។

ខ្ញុំមិនចងពៀរនឹងអ្នកទេ ជង្រុករបស់ខ្ញុំក៏មិនមានដែរ ខ្ញុំដោះបំណុល ផង ឲ្យបុលផង ខ្ញុំហើរទៅដល់ចុងរកា ក៏កប់កំណប់ទុកក្នុងព្រៃរកា នោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ។

គ្រានោះ (ដោយមិនយល់) ព្រាហ្មណ៍ក៏សួរទៅទៀតថា៖

កីទិសំ តេ ឥណាទានំ ឥណមោក្ខោ ច កីទិសោ

និធិនិធានមក្ខាហិ　　អថ បាសា បមោក្ខសិ ។

ការឲ្យបុលរបស់អ្នកដូចម្តេច ការដោះបំណុលដូចម្តេច ចូរអ្នកប្រាប់ នូវការកប់កំណាប់ កាលបើដូច្នោះ អ្នកនឹងរួចចាកអន្ទាក់ ។

កាលបើ ព្រាហ្មណ៏សួរយ៉ាងនេះហើយ ស្តេចសេកក៏ដោះស្រាយ បញ្ហានោះចំនួន៤គាថាដូច្នេះ៖

អជាតបក្ខា តរុណា　　បុត្តកា មយ្ហំ កោសិយ

តេ មំ ភតា ភរិស្សន្តិ　　តស្មា តេសំ ឥណំ ទទេ ។

បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗ មិនទាន់ដុះស្លាបនៅឡើយ កូនតូច ទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយនឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំត្រូវឲ្យបុល ដល់កូនតូចៗ ទាំងនោះ ។

មាតា បិតា ប មេ វុឌ្ឍា　　ជិណ្ណកា កតយោព្វនា

តេសំ តុណ្ហេន ហាត្វន　　មុញ្ចេ បុព្វកតំ ឥណំ ។

ម្យ៉ាងទៀត ខ្ញុំមានមាតាបិតាចាស់គ្រាំគ្រា មានវ័យកន្លងហើយ ខ្ញុំពាំ (នូវស្រូវសាលី) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំត្រូវដោះ បំណុលដែលគាត់ធ្វើហើយមុន ។

អញ្ញេបិ តត្ថ សកុណា ទីណបក្ខា សុទុព្វលា

តេសំ បុញ្ញត្ថិកោ ទម្មិ តំ និធឹ អាហុ បណ្ឌិតា ។

ក្នុងព្រៃរកានោះមានបក្សីទាំងឡាយដទៃទៀត ដែលជ្រុះស្លាបអស់ ហើយថមថយកម្លាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ បណ្ឌិតទាំងឡាយពោលថា បុញ្ញកម្មនោះជាកំណប់ ។

ការឲ្យបុលរបស់ខ្ញុំយ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំយ៉ាងនេះ ខ្ញុំ ប្រាប់នូវការកប់កំណប់ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះ ។

ព្រាហ្មណ៍បានស្តាប់នូវធម្មកថារបស់ព្រះមហាសត្វហើយ ក៏មានចិត្ត ជ្រះថ្លា ពោលសរសើរពីរគាថាដូច្នេះថា៖

ភទ្ទកោ វតាយំ បក្ខី ទិជោ បរមធម្មិកោ

ឯកច្ចេសុ មនុស្សេសុ អយំ ធម្មោ ន វិជ្ជតិ

បក្សីមានកំណើតពីរដងនេះប្រសើរណាស់តើ ជាសត្វប្រកបដោយ ធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះមិនមានធម៌នេះទេ ។ ចាប់ពីថ្ងៃនេះទៅ ចូរអ្នកកុំភ័យ យើងឲ្យស្រូវទាំង ៤០០ហិចតាដល់អ្នក អ្នកចូរបរិភោគនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់តាមសេចក្តីប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញ

អ្នកទៀត ដ្បិតការបានជួបប្រទះនឹងអ្នក (នេះ) ជាទីស្រឡាញ់របស់យើង។ ព្រាហ្មណ៍កាលពោលអង្វរយ៉ាងនេះ សម្លឹងមើលមហាសត្វដោយ ចិត្តដ៏ទន់ភ្លន់ ប្រៀបបាននឹងមើលកូនរបស់ខ្លួន បានស្រាយចំណងជើងលាបប្រេងថ្នាំរាប់ រយដង រួចឲ្យស្ដេចសេកទំលើតុដ៏ប្រសើរ លាយលាជនឹង ទឹកឃ្មុំដាក់ក្នុងថាស មាសឲ្យបរិភោគ និងឲ្យផឹកទឹកស្ករគ្រួស។ នៅគ្រានោះ ស្ដេចសេកក៏ពោលថា "ម្នាលព្រាហ្មណ៍ ចូរអ្នកកុំប្រមាទ" ហើយកាលឲ្យឱវាទដល់ព្រាហ្មណ៍ ក៏ពោល គាថានេះថាៈ

បពិត្រកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅអ្នករួចហើយ ខ្ញុំមិន អាចនឹងនៅក្នុងសំណាក់នៃអ្នកអស់រាត្រីមួយទេ អ្នកចូរឲ្យទាន (ចំពោះ សមណៈព្រាហ្មណ៍)ដែលមានអាជ្ញាដាក់ចុះហើយផង ចូរចិញ្ចឹម មាតាបិតា ដែលចាស់គ្រាំគ្រាផង ។ ព្រាហ្មណ៍បានស្ដាប់ហើយមានចិត្ត ត្រេកអរក៏បន្លឺ ឧទានវាចាយ៉ាងនេះថាៈ

លក្ខី (សិរី បុណ្យ និងប្រាជ្ញា) បានកើតឡើងហើយដល់យើងក្នុងថ្ងៃនេះដ្បិត យើងបានជួបនឹងស្ដេចសេកដ៏ប្រសើរជាងពួកបក្សីទាំងឡាយ យើងនឹងធ្វើ បុណ្យឲ្យបានច្រើនព្រោះបានស្ដាប់នូវសុភាសិតរបស់សេក។

ព្រះមហាសត្វ (ជាសត្វដឹងប្រមាណ) ទទួលយកស្រែស្រូវតែ ៣ហិចតាកន្លះ ប៉ុណ្ណោះ អំពីស្រូវទាំងអស់ ៤០០ហិចតា ដែលព្រាហ្មណ៍ បានបោះបង្គោលព្រំ ប្រគល់ឲ្យ ទាំងបូជា សុំខមាទោសព្រះអង្គដោយគ្រឿងក្រអូប និងផ្កាកម្រងជា

ដើម ហើយបានជូនដំណើរស្ដេចសេកដោយពាក្យថា នែ! អ្នកជាធំ! អ្នកចូរទៅចុះ ចូរបានជួបមាតាបិតារបស់អ្នកដែលកំពុងយំរង់ចាំអ្នក។ ស្ដេចសេកមានចិត្តរីករាយ ពាំយកកួរ ស្រូវសាលីមកដាក់ខាងមុខមាតាបិតា ដោយពោលពាក្យថា អ្នកម្ដាយ លោកឪពុក! ក្រោកឡើង! ពួកគាត់មានមុខទទឹក ដោយទឹកភ្នែកយំខ្សឹកខ្សួលក្រោកឡើង ទាំងហ្វូងសេកក៏បានជួបជុំគ្នាពេលនោះ សួរនាំថា តើព្រះអង្គរួចពីអន្ទាក់បានយ៉ាងម៉េចទៅព្រះអង្គ ? ស្ដេចសេកបាន រ៉ាយរាប់ប្រាប់ដោយសព្វគ្រប់។

ថ្ងៃងពីកោសិយព្រាហ្មណ៍ក្រោយពីបានស្ដាប់ឱវាទស្ដេចសេកហើយ ក៏បានតាំងឡើងនូវមហាទានដល់ពួកសមណៈព្រាហ្មណ៍ដ៏ប្រកបដោយធម៌ផងដែរ ។ ព្រះបរមគ្រូកាលទ្រង់ប្រកាសសេចក្ដីនុ៎ះ ទើបសម្ដែងនូវ ឱសានគាថាៈ សាលិន្ទិយព្រាហ្មណ៍ជាកោសិយគោត្រនោះ មានចិត្តរីករាយ មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានចាត់ចែងនូវបាយ និងទឹក ហើយញ៉ាំង សមណៈនិងព្រាហ្មណ៍ទាំងឡាយឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក។

ព្រះសាស្ដាលើកធម្មទេសនានេះមក ដោយចង់បញ្ជាក់ថា ភិក្ខុដែល បានចិញ្ចឹមមាតាបិតាអង្គនេះ ជាពូជពង្សនៃអ្នកប្រាជ្ញទាំងឡាយ រួចទ្រង់ ប្រជុំជាតកប្រកាសសច្ចធម៌ ភិក្ខុអង្គនោះ ក៏បានលុះក្នុងសោតាបត្តិផល ហ្វូងសេកក្នុងកាលនោះ បានមកជាបរិស័ទឥឡូវនេះ មេបាស្ដេចសេក បានមកជាពុទ្ធមាតា

បិតា នាយរក្សាស្រែបានជាឆន្នះ កោសិយព្រាហ្មណ៍ ជាព្រះអានន្ទ ឯស្ដេចសេកពោធិសត្វគឺអង្គតថាគតគ្រានេះឯងហោង៕

រឿងស្រែស្រូវសាលី ចប់ ៕

## អវសានកាព្យ

ដោយភាពកតញ្ញូ ចំពោះមាតា សេកព្រះរាជា បានរួចអន្ទាក់
នាយរក្សាស្រែប្រឹងដាក់ចាប់ទាក់ ព្រាហ្មណ៍កោសិយៈសន្ដោសប្រណី
ហៃ! អស់សាធុជនទាំងឡាយអើយ ចូរកុំកន្ដើយ ទាំងប្រុសទាំងស្រី
ចូររៀនដឹងគុណ ចិញ្ចឹមឪពុកម្ដាយ កុំបីដោះដៃ ឲ្យគាត់សោកា ។
បើកូនចៅបាន គោរពប្រតិបត្តិ បម្រើពួកគាត់ ដូចរឿងនេះណា
អ្នកនឹងបានរួច ចាកក្ដីហាយនា សោយសុខសួគ៌ា រមនាទៅហោង។

ថ្ងៃពុធ ទី ២៨ កញ្ញា ព.ស.២៥៥៥

គ.ស. ២០១១

# ពន្យល់ពាក្យ

| | | |
|---|---|---|
| កតញ្ញូ | ការដឹងគុណដែលអ្នកដទៃធ្វើហើយ | |
| កាលពីព្រេងនាយ | ពេលវេលាដ៏យូរណាស់ហើយ | Es war einmal... |
| កួរស្រូវ | ចង្កោមផ្លែ, សំណុំផ្លែស្រូវ | Menge Reis |
| ទ្រង់គង់ | ស្នាក់នៅ | wohnen |
| គ្រហស្ថ | អ្នកគ្រប់គ្រងផ្ទះ | Haushaltsvorstand |
| ត្រាច់គោចរ | ហើរស្វែងរកអាហារ | suchen essen |
| ថ្លែងវិយោគ | ពោលរៀបរាប់ពីការបែកព្រាត់ប្រាស ចាកអ្នកជាទីស្រឡាញ់ | Leiden sagen |
| ទូលពុទ្ធដីកា | ជំរាប ឬថ្លែងប្រាប់ដល់ព្រះពុទ្ធ | sagen |
| ធម្មកថា | ការពោលដោយធម៌ | Wahrheitsrat |
| ព្រះបរមសាស្ដា | ព្រះជាគ្រូដ៏ប្រសើរនៃទេវតា និងមនុស្សទាំងឡាយ | Grosser Lehrer |
| បាបកម្ម | អំពើអាក្រក់ | Sünde |

| | | |
|---|---|---|
| ប្រារព្ធ | ដំណាលរឿងGeschichte versprechen | |
| បំណុល | ទ្រព្យដែលជំពាក់គេ, ខ្ចីគេ | Schuld |
| ពុទ្ធបរិស័ទ | ពួកជនដែលស្ម័គ្រស្មោះនឹងព្រះពុទ្ធ Jünger des Buddha | |
| មាតាបិតា | ម្ដាយ ឪពុក, ម៉ែ ពុក | Eltern |
| ភិក្ខុ | អ្នកបួសក្នុងព្រះពុទ្ធសាសនា | Mönch |
| រមនា | សុខក្សេមក្សាន្ត, សប្បាយរីករាយ | |
| រាជគ្រឹះ | ទីក្រុងមួយរបស់ឥណ្ឌា | Raigir |
| ព្រះរាជា | ស្ដេច | König |
| សច្ចធម៌ | សេចក្ដីពិត, ធម្មជាតិ | Wahrheit |
| សត្វតិរច្ឆាន | សត្វមានរាងកាយចម្រើនដោយទទឹង | Tier |
| សន្ដោសប្រណី | ប្រោសប្រាណ, អាណិតអាសូរ | |
| សោកា | ទុក្ខក្រៀមក្រំ | |
| សួគ៌ា | កន្លែងមានសេចក្ដីសុខសប្បាយ | |

| | | |
|---|---|---|
| សោយរាជ្យ | គ្រប់គ្រងប្រទេសជាស្ដេច<br>Herrschaft das Reich | |
| ស្រូវសាលី | ស្រូវខ្សាយ | Reis |
| ហាយនា | ហិនហោច, វិនាស, អន្តរាយ | |
| ហ្វូង | ក្រុម, ពួក | Group |
| អាណាខេត្រ | ដែនគ្រប់គ្រងរបស់ស្ដេច | Land |
| អំពើលាមក | អំពើអាក្រក់, គួរឲ្យខ្ពើម Sünde | |
| ភាគឦសាន្ត | ទិសខាងជើងឆៀងខាងកើតNordosten | |
| ឱវាទ | ពាក្យទូន្មានប្រៀនប្រដៅ | Ermahnung |
| ឱសានគាថា | គាថា ឬឃ្លាចុងក្រោយ, អវសាន | |

# រឿងភិក្ខុចិញ្ចឹមម្ដាយ[៣]

កិរៈ បានឮមកថានៅក្រុងសាវត្ថីមានត្រកូលសេដ្ឋីមួយមានទ្រព្យ ១៨កោដិ មានកូនប្រុសតែមួយជាទីស្រឡាញ់ពេញចិត្តនៃម្ដាយឪពុក។ នៅ រសៀលថ្ងៃមួយ មាណពនោះបានឡើងទៅលើប្រាសាទដ៏ប្រសើរ បើក បង្អួចសំឡឹងទៅកាន់ដងវិថី ក៏ឃើញមហាជនមានដៃកាន់គ្រឿងក្រអូប និងផ្កាកម្រងជាដើម ដើរតម្រង់ទៅវត្តជេតពន ដើម្បីស្ដាប់ព្រះធម៌ លុះឃើញយ៉ាងនេះ ហើយក៏គិតថា អាត្មាអញនឹងទៅស្ដាប់ធម៌នឹងគេដែរ រួចក៏ចុះទៅថ្វាយបង្គំគោរពលាម្ដាយឪពុក ឲ្យគេជួយកាន់គ្រឿងក្រអូប និងផ្កាជាដើមទៅវិហារ ប្រគេនសំពត់ ភេសជ្ជៈ ទឹកផ្លែឈើជាដើមដល់ព្រះសង្ឃ និងបូជាព្រះដ៏មានព្រះភាគ ដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ហើយក៏អង្គុយស្ដាប់ធម៌ត្រង់កន្លែងសមគួរមួយ លុះបានស្ដាប់ធម៌ បានឃើញនូវទោសក្នុងកាមទាំងឡាយនិងសំឡឹងឃើញអានិសង្សនៃផ្នួសតាមពិត។ នៅពេលដែលបរិស័ទក្រោកចេញអស់ ក៏បានទូលសុំព្រះដ៏មានព្រះភាគបួស។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា ធម្មតា! តថាគតមិនដែលបំបួសកុលបុត្រ ដែលម្ដាយឪពុកមិនទាន់បានអនុញ្ញាតឡើយ ឮដូច្នេះ មាណពកម្លោះ ក៏ថ្វាយបង្គំលាព្រះដ៏មានព្រះភាគទៅគេហដ្ឋានសិន រួចក៏ថ្វាយបង្គំសុំមាតាបិតាទៅបួសដោយសេចក្ដីគោរពយ៉ាងនេះថា ម៉ែ!ពុក! កូនសុំទៅ

---

[៣]សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកាទសមភាគ ៦២ ទំព័រ ៤៩

បួសក្នុងសំណាក់ព្រះមានព្រះភាគហើយ! ម្ដាយ ឪពុកគ្រាន់តែឮពាក្យកូនពោលដូច្នោះ ហាក់ដូចជាប្រេះបេះដូងជា ៧ចំណែក ញ័រចំប្រប់ ព្រោះតែស្រឡាញ់កូនដែលមានតែមួយ។ ហើយពោលតបទៅកូនវិញថា កូនសំឡាញ់ កូនគឺជាកូនជាទីស្រឡាញ់តែម្នាក់គត់ ជាទីសង្ឃឹមនៃត្រកូល ជាភ្នែក ជាថ្លើមប្រម៉ាត់ បា! ប្រៀបបាននឹងខ្លួនប្រាណ សាច់ឈាម តើឲ្យម្ដាយឪពុករស់នៅដោយគ្មានកូនម្ដេចបាន ជីវិតម៉ែឪពឹងលើកូនទាំងស្រុងហើយ! កូនសំឡាញ់! ម្យ៉ាង ម៉ែឪចាស់គ្រាំគ្រាហើយ មានវ័យចម្រើនទ្រុឌទ្រោមហើយ មិនដឹងថាស្លាប់ថ្ងៃនេះថ្ងៃស្អែកឬខានស្អែកនោះទេ ព្រោះហេតុនោះ ចូរបាកុំទៅចោលពួកយើងឡើយ! ហៃបា! ធម្មតាការបួសលំបាកណាស់ ត្រូវការត្រជាក់បែរជាបានក្ដៅ ត្រូវការក្ដៅទៅជាបានត្រជាក់វិញ ហេតុនេះ ចូរបាកុំទៅ បួសអី!

កូនកំលោះបន្ទាប់ពីស្ដាប់ពាក្យរៀបរាប់នុ៎ះ ក៏កើតទុក្ខទោមនស្ស ឈ្ងោកមុខចុះ អង្គុយសញ្ជឹងគិតអត់អាហារអស់៧ថ្ងៃ។ គ្រានោះ ម្ដាយឪពុកគិតគ្នាថា បើយើងមិនឲ្យកូនទៅបួសទេ វាប្រាកដជាស្លាប់មិនខាន ហើយយើងនឹងលែងបានឃើញវាទៀតដែរ បើឲ្យវាទៅបួសទៅគ្រាន់ សល់ជីវិតនៅបានឃើញមុខតទៅទៀត ។ លុះគិតដូច្នោះហើយ ក៏បានអនុញ្ញាតឲ្យកូនបួសដោយពាក្យថា កូនពៅសំឡាញ់ម្ដាយ! កូនបួសចុះ! ម៉ែពុកព្រមឲ្យកូនបួសហើយ។ អ្នកកម្លោះគ្រាន់បានឮថាព្រមឲ្យបួសហើយ ក៏មានចិត្តសប្បាយងូត ទឹកជម្រះរាងកាយ ថ្វាយបង្គំលាមាតាបិតា ដើរទៅកាន់វិហារ ទូលសុំ ព្រះដ៏មាន

ព្រះភាគបួស ។ ព្រះសាស្តាក៏ត្រាស់បង្គាប់ភិក្ខុមួយអង្គឲ្យបំបួសកុមារនេះ ហើយភិក្ខុនោះ ក៏បានបំបួសកុមារនោះទៅ ។ ចាប់តាំងពីបានបួសមក សាមណេរនោះមានលាភសក្ការច្រើន តមកក៏សុំអាចារ្យ និងឧបជ្ឈាយ៍បាន ឧបសម្បទា (បួសជាភិក្ខុ)។ នៅរៀនបម្រើអស់ ៥វស្សា ក៏គិតថាខ្លួននៅទីនេះ ច្របូកច្របល់ណាស់ មិនអាចនឹងនៅយ៉ាងនេះរហូតទេ។ ដោយប្រាថ្នានឹង បំពេញវិបស្សនាធុរៈ បានសុំកម្មដ្ឋានពីសំណាក់ព្រះឧបជ្ឈាយ៍ ថ្វាយបង្គំលា ចេញចាកវត្តជេតពន ទៅរស់អាស្រ័យនៅក្នុងព្រៃឯស្រុកដាច់ស្រយាលមួយ។ ភិក្ខុនោះទោះជាខិតខំព្យាយាមដុសខាត់ ចម្រើនវិបស្សនារហូតអស់ ១២ឆ្នាំ ក៏ដោយ ក៏នៅមិនបានសម្រេចគុណវិសេសអ្វីសោះ។ រីឯមាតាបិតារបស់លោក ដោយពេលវេលាចេះតែកន្លងទៅៗ ក៏ធ្លាក់ខ្លួនទ័លក្រលំបាកដោយសារ តែអ្នកជួលដីស្រែ អ្នកធ្វើពាណិជ្ជកម្មជាមួយ លួចប្រវ័ញ្ចន៍យកទ្រព្យទៅ ព្រោះគេគិតថា ក្នុងត្រកូលនេះ គ្មានកូន គ្មានបងប្អូន គ្មានអ្នកទារបំណុលអីទេ ហើយអ្នកបំរើក្នុងផ្ទះទៀតសោត ក៏លួចយកប្រាក់មាសជាដើមរត់ចោលអស់។

ទីបំផុត អ្នកទាំងពីរក៏ធ្លាក់ខ្លួនទ័លក្រ មិនមានសូម្បីតែផ្តិលសម្រាប់ ដួសទឹកក្នុងដៃ ក៏លក់ផ្ទះទៀត រស់នៅឥតមានផ្ទះសម្បែង ដល់នូវភាព គួរឲ្យអាណិតពន់ពេក ស្លៀកសម្លៀកបំពាក់ចាស់ៗ ដៃកាន់អំបែងដើរ សុំទានគេ។ ក៏កាលនោះ មានភិក្ខុមួយអង្គធ្វើដំណើរពីវត្តជេតពន ទៅតាមលំដាប់ បានដល់កន្លែង

ដែលភិក្ខុកម្លោះនោះគង់នៅ ភិក្ខុកម្លោះនោះ ក៏បានធ្វើកិច្ចវត្តចំពោះលោកជាអ្នកមកដល់ថ្មី ឲ្យគង់ក្នុងទីស្រួល សមរម្យហើយក៏សួរថា៖

លោកម្ចាស់! និមន្តមកពីខាងណាដែរទាន? អាគន្តុកភិក្ខុតបថា អ្នកមានអាយុ! ខ្ញុំករុណាមកពីវត្តជេតពន! បានស្តាប់ដូច្នោះ ក៏សួរសុខទុក្ខ (ភាពមិនមានរោគ) ពីព្រះសាស្តា និងមហាសាវ័កទាំងឡាយជាដើម រួចក៏សួរពីដំណឹងញោមស្រីប្រុស (មាតាបិតា) របស់លោកថា បពិត្រលោកម្ចាស់! ចុះត្រកូលសេដ្ឋីមួយនៅម្តុំនោះនាក្រុងសាវត្ថីដែរ មានសុខទុក្ខយ៉ាងណាដែរ? អាគន្តុកភិក្ខុតបថា ហ៊ឺ! អាវុសោ! ចូរលោកកុំ សួរដំណឹងពីត្រកូលនោះអី! ហេតុអីទៅលោកម្ចាស់? ភិក្ខុកម្លោះសួរបញ្ជាក់។ លោកតបថា ម្នាលអាវុសោ ឮថា ត្រកូលហ្នឹងមានកូនតែមួយ ហើយកូននុ៎ះក៏បានបួសក្នុងព្រះពុទ្ធសាសនាទៅហើយ ចាប់ពីពេលដែលកូននោះបួសមក ត្រកូលនោះក៏រលំរលាយអស់ទៅ ឥឡូវជន ទាំងពីរជាម្តាយឪពុករងទុក្ខគួរឲ្យអាណិតក្រៃពេក ដេកដើរសុំគេរស់។ លោកកូនគ្រាន់តែបានឮភិក្ខុអង្គនោះប្រាប់ភ្លាមហាក់មិនអាចនឹងទប់ខ្លួនឯងបាន ទើបស្រែកយំទាំងទឹកភ្នែករហាម។ អាវុសោ! ម៉េចបានលោក យំចឹង? អាគន្តុកភិក្ខុសួរ។ ក៏ឆ្លើយទាំងអណ្តឺតអណ្តកថា លោកម្ចាស់! ពួកគាត់ជាញោមស្រីញោមប្រុសរបស់ខ្ញុំព្រះករុណាៗត្រូវជាកូនគាត់។ អាគន្តុកភិក្ខុដាស់តឿនថា នែ អាវុសោ! ញោមស្រីប្រុសរបស់លោកធ្លាក់ខ្លួន (យ៉ាងនេះ) ក៏ព្រោះតែលោក! ទៅ! ទៅមើលថែពួកគាត់វិញ!

ភិក្ខុកម្លោះសញ្ជឹងគិតម្នាក់ឯងថា ហ៊ឺ! អាត្មាអញហ្អើយ! ហៅពេញជាបុគ្គលអភ័ព្វណាស់! ខំប្រឹងព្យាយាមដុសខាត់សម្អាតចិត្តអស់១២ឆ្នាំ នៅតែមិនបានសម្រេចមគ្គផលអ្វីសោះ! តើអញបួសធ្វើអ្វីទៀត! សឹក ទៅជាគ្រហស្ថចិញ្ចឹមបម្រើម្តាយឪពុក ឲ្យទាន (រក្សាសីល) វិញ ក្រែងលោបានផ្លូវទៅឋានសួគ៌ខ្លះ! គិតរួច ក៏ប្រគល់ខ្ទមក្នុងព្រៃទៅព្រះថេរៈអង្គនោះ ព្រឹកឡើងព្រលឹមស្រាងៗ ក៏និមន្តចេញចាកព្រៃតាមលំដាប់ ទៅដល់របងវិហារវត្តជេតពនមិនឆ្ងាយប៉ុន្មានពីក្រុងសាវត្ថី ត្រង់នុ៎ះមានផ្លូវពីរ ១ទៅវត្តជេតពន ឯ១ទៀតទៅកាន់ក្រុងសាវត្ថី។ លោកឈរគិតមួយសន្ទុះ "តើអាត្មាអញទៅជួបញោមទាំងពីរមុន ឬក៏ទៅគាល់ព្រះទសពលមុន!„ រួចក៏សម្រេចចិត្តថា "ញោមស្រីប្រុស អញគប្បីនៅមើលថែគាត់បានយូរទៀត តែចាប់ពីពេលនេះទៅ អាត្មាអញនឹងមិន សូវបានឃើញព្រះសម្ពុទ្ធញឹកញាប់ទេ! បើអញ្ចឹង! ថ្ងៃនេះ អញនឹងទៅ ជួបព្រះសម្មាសម្ពុទ្ធស្តាប់ធម៌សិន ព្រឹកស្អែកសឹមទៅជួបអ្នកមានគុណទាំងពីរ" ក៏បែរចេញពីផ្លូវទៅសាវត្ថី ហើយថ្ងៃរសៀលបន្តិចក៏បានទៅដល់វត្តជេតពន។ នៅថ្ងៃនោះដែរ ព្រះសាស្តាកាលទ្រង់ប្រមើលមើលសត្វលោកនាបច្ចូសសម័យ ក៏ឃើញថា ឧបនិស្ស័យនៃកុលបុត្រនោះ ដល់ព្រមល្មមគ្រប់គ្រាន់ហើយ។ នៅគ្រាដែលភិក្ខុអង្គនោះមកដល់ ព្រះអង្គក៏សម្តែងមាតុបោសកសូត្រ[៤] ពោលសរសើរគុណមាតាបិតា។ ភិក្ខុអង្គនោះឈរស្តាប់ធម្មកថាព្រះសាស្តា នៅខាង

---

[៤]សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ទុតិយភាគ ៣០ ទំព័រ ១៤១

ចុងភិក្ខុបរិស័ទ គិតថា "អាត្មាអញគិតថា សឹកទៅអាចបានបម្រើម្ដាយឪពុក! តែព្រះបរមគ្រូត្រាស់ថា អ្នកបួសហ្នឹងឯង ក៏អាចទំនុកបម្រុងធ្វើនូវ ឧបការៈចំពោះម្ដាយឪពុកបានដែរតើ! អស្ចារ្យ! បើអញអត់មកជួបព្រះសាស្ដាទេ ប្រហែលជាអញសឹកបាត់ទៅហើយ តែឥឡូវ! អស់អីហើយ! អញមិន ចាំបាច់សឹកទេ នៅជាអ្នកបួសដដែលក៏អាចចិញ្ចឹមញោមទាំងពីរនាក់បានដែរ"។

ភិក្ខុកម្លោះនោះ ធ្លាប់នៅក្នុងព្រៃចំនួន ១២ឆ្នាំ តែឥរិយាបថហាក់ដូចជាភិក្ខុចាលចាញ់ ឥតមានភាពខ្មាស់អៀន ទៅកាន់រោងសលាកភត្ត យកសលាកបាយផង សលាកបបរផង និមន្តចូលទៅកាន់ក្រុងសាវត្ថីតាំងពីព្រឹកព្រហាម។ (នៅតាមផ្លូវ) លោកគិតថា អញគួរទៅយកបបរមុន ឬទៅជួបញោមស្រីប្រុសមុនហ្ន៎! ក៏នឹកឃើញថា ម្ដាយឪពុកក្រម្លឹងៗ ទៅជួបគាត់ដៃទទេម្ដេចនឹងកើត! រួចក៏ទទួលបបរនិមន្តទៅកាន់ទ្វារផ្ទះចាស់របស់លោក។ ញោមស្រីប្រុសរបស់លោកស្នាក់នៅតាមរបងផ្ទះអ្នកដទៃ ក៏កំពុងដើរសុំបបរគេពិសាដែរ។ លោកកូននិមន្តទៅជិត ឃើញញោមទាំងពីរអង្គុយកៀកគ្នាយ៉ាងនេះ កើតទុក្ខក្ដុកក្ដួលស្រក់ទឹកភ្នែកដោយមិនបានព្រាងទុក ក៏និមន្តទៅឈរជិតអ្នកទាំងពីរ។ ពួកគាត់សូម្បីបានឃើញលោកហើយ តែមិនបានជាស្គាល់ថា ជាលោកកូនរបស់គាត់ទេ។ ពេលនោះ ញោមស្រីសំគាល់ថា លោកនិមន្តមកឈរទ្រទង់បាត្រ ក៏ពោលថា "ព្រះគុណម្ចាស់! ពួកខ្ញុំព្រះករុណាគ្មានអ្វី ដាក់បាត្រ

ទេ សូមនិមន្តទៅមុខទៀតចុះ! លោកកូនឮពាក្យម្ដាយដូច្នោះ ចុកណែនដើមទ្រូងស្រក់ទឹកភ្នែកម៉ាត់ៗ ទប់ខ្លួនឈរនៅទីនោះឯង ។

នៅពេលដែលញោមស្រីពោលពីរបីដងហើយ លោកនៅតែឈរកន្លែងដដែលយ៉ាងនេះ ញោមប្រុសភ្លាមនុ៎ះ ក៏និយាយនឹងញោមស្រីថា នែ! នាង! មកមើលមើល៍! ហ្នឹង! កូនយើងមែន ឬមិនមែនហ្នឹង! ញោមស្រីក្រោកដើរទៅមើលជិត ស្គាល់ច្បាស់ថាជាកូន ក៏ទម្លាក់ខ្លួន យំរៀបរាប់ទៀបជើងលោក ទាំងពីរនាក់មើលទៅគួរឲ្យអាសូរក្រៃពេក។

សូម្បីលោកកូនកាលឃើញញោមស្រីប្រុសយំយែកដូច្នោះ ក៏មិន អាចនឹងទប់ខ្លួនមិនឲ្យស្រក់ទឹកភ្នែកបានឡើយ តែលោកខំទប់សេចក្ដីសោក ត្រឡប់ជាលួងលោមញោមទាំងពីរឲ្យធូរស្បើយ ដោយធានាអះអាងថា "ម៉ែ! ពុក! ឈប់គិតទៅ! (ចាប់ពីថ្ងៃនេះទៅ) កូននឹងចិញ្ចឹម លោកទាំងពីរណា៎! រួចក៏ឲ្យគាត់ពិសាបបរដែលខ្លួននាំមក។ (ក៏បាន) ឲ្យពួកគាត់អង្គុយត្រង់កន្លែងសមរម្យ ខ្លួនឯងទៅយកបាយម្ហូបមកជូនពួកគាត់ពិសាទៀត រួចទើបបាននិមន្តទៅរកបិណ្ឌបាត្រសម្រាប់ខ្លួនឯង (បានហើយ) ក៏ទៅជួបញោមទាំងពីរជូនគាត់ពិសាម្ដងទៀត ទុកណាជាគាត់មិនត្រូវការក៏ដោយ ហើយទើបលោកឆាន់តាមក្រោយ (នូវអាហារដែលសេសសល់) ។ ភិក្ខុកម្លោះរូបនេះ ទំនុកបម្រុងមាតាបិតាតាមទំនងនេះចាប់ពីពេលនោះរហូតមក ទោះជាខ្លួនបានភត្តផ្សេងៗ មានភត្ត ដែលព្រះភត្តុទ្ទេសកៈចាត់តាមវេនដែលគេនិមន្តជាដើម ក៏លោកយក ទៅជូនញោម

អស់ៗ ហើយខ្លួនលោកផ្ទាល់និមន្តដើររកបិណ្ឌបាត បានក៏ឆាន់ បើមិនបានក៏អត់ឆាន់ទៅ សម្រាប់ថ្ងៃដែលបានមានតិចទេ រីឯថ្ងៃដែលអត់គឺច្រើន។ សូម្បីសំពត់សាដក និងរបស់របរតិចតួចយ៉ាងណាក៏ដោយ ឲ្យតែបានមក ក៏ជូនទៅញោមទាំងអស់ រីឯលោករើសយកតែកំណាត់សំពត់ចាស់ៗ ដែលគេប្រើហើយមកដេរប៉ះជ្រលក់ប្រើខ្លួនឯង ដូច្នោះហើយ ស្បង់ចីពរ (រូបរាង) ក៏ទៅជាសៅហ្មងមិនគួរឲ្យមើល។

ភិក្ខុកម្លោះនោះ ដោយសារតែទំនុកបម្រុងមាតាបិតាយ៉ាងនេះ តមក លោកទៅជាកើតរោគលឿង ស្លេកស្លាំង ស្គាំងស្គម ចេញសរសៃរវាម គ្រានោះ ពួកភិក្ខុជាមិត្រស្និទស្នាល និងមិត្រធ្លាប់ជួបគ្នាម្ដងម្កាលបានសួរលោក ថា "អាវុសោ! ពីមុនលោកមានពណ៌សម្បុរកាយស្អាតបាត ល្អជាតើ! ចុះម្ដេចឥឡូវ! ទៅជាកើតរោគលឿង ស្លេកស្លាំង ស្គាំងស្គម ចេញសរសៃរវាមចឹង? លោកមានជំងឺឬ?" លោកក៏ឆ្លើយប្រាប់រឿងរ៉ាវនុ៎ះថា "អាវុសោ! ខ្ញុំព្រះករុណា គ្មានជំងឺអ្វីទេ ប៉ុន្តែមានបលិពោធតិចតួច"។ លំដាប់នោះ ភិក្ខុទាំងនោះក៏ស្ដីបន្ទោសភិក្ខុកម្លោះនោះថា "ម្នាលលោកដ៏មានអាយុ! ព្រះដ៏មានព្រះភាគ បានហាមមិនឲ្យភិក្ខុញុំាង សទ្ធាពុទ្ធបរិស័ទឲ្យធ្លាក់ចុះទេ ចុះម្ដេចក៏លោកយករបស់ដែលបានមក ដោយសទ្ធាឲ្យទៅពួកគ្រហស្ថយ៉ាងនេះ ធ្វើអញ្ចឹង! មិនត្រូវទេ!" ភិក្ខុកម្លោះឮដូច្នោះ ក៏ខ្មាស់អៀនឱនមុខជ្រប់។ ភិក្ខុទាំងនោះ ដោយហេតុសូម្បីប៉ុណ្ណឹង ក៏មិនពេញចិត្ត នាំរឿងទៅទូលពិតព្រះដ៏មានព្រះភាគ ជាសាស្ដា

ថា "បពិត្រព្រះអង្គដ៏ចម្រើន! មានភិក្ខុមួយអង្គនោះចិញ្ចឹមគ្រហស្ថ ធ្វើសទ្ធាទាយកឲ្យធ្លាក់ចុះព្រះអង្គ! ទើបព្រះសាស្ដាឲ្យគេហៅ ភិក្ខុនោះមកត្រាស់សួរថា "ម្នាលភិក្ខុ! ឮថា អ្នកយករបស់ដែលទាយក ឲ្យដោយសទ្ធាទៅចិញ្ចឹមគ្រហស្ថពិតមែនឬ? “បពិត្រព្រះអង្គដ៏ចម្រើន រឿងនុ៎ះពិតយ៉ាងហ្នឹងមែន ព្រះអង្គ!” ភិក្ខុកម្លោះតបពុទ្ធដីកា ។

ព្រះសម្មាសម្ពុទ្ធដោយទ្រង់មានព្រះបំណងចង់ពណ៌នាសរសើរនូវ កិរិយានុ៎ះផង ចង់ប្រកាសបុព្វចរិយារបស់ព្រះអង្គផង ទើបត្រាស់សួរតទៅទៀតថា “ម្នាលភិក្ខុ! តើគ្រហស្ថដែលអ្នកចិញ្ចឹមនោះ ត្រូវជាអ្វីនឹងអ្នកដែរ?” ភិក្ខុនោះឆ្លើយថា "បពិត្រព្រះអង្គដ៏ចម្រើន! ពួកគាត់ ត្រូវជាញោមស្រីប្រុសរបស់ខ្ញុំព្រះអង្គ"។ ដើម្បីលើកទឹកចិត្តភិក្ខុកម្លោះនុ៎ះ ព្រះអង្គទ្រង់ឲ្យពរសាធុការ ៣ដងថា "សាធុ! សាធុ! ប្រពៃហើយៗ ភិក្ខុ" អ្នកដើរត្រូវតាមផ្លូវរបស់តថាគតហើយ! សូម្បីតថាគតក៏ប្រព្រឹត្តបុព្វចរិយា ចិញ្ចឹមមាតាបិតាដូចអ្នកយ៉ាងនេះដែរ។ ភិក្ខុកម្លោះនោះ ក៏បានធូរទ្រូងសប្បាយរីករាយទៅហោង។

រឿងភិក្ខុចិញ្ចឹមមាតា ចប់ ៕

## អវសានកាព្យ

រីព្រះជិនស្រី អង្គថ្លៃប្រសើរ ទ្រង់មានដំណើរ ដ៏ល្អម៉ដ្ឋហ្មង

ធ្វើទានមានសីល ឥតរមិលគុណផង ដើរតាមគន្លង នៃព្រះអតីតពុទ្ធ ។

ភិក្ខុកម្លោះ ពិតស្មោះសាសនា ចិញ្ចឹមមាតា ជីវីបរិសុទ្ធ
ដើរតាមទំនៀម នៃព្រះចមម្កុដ ល្អល្អះខ្ពស់ផុត អស់គុណទាំងឡាយ ។
ហៃ! សាធុជន បុរសស្ត្រី នៅស្មៀមធ្វើអ្វី ចូរខំខ្វល់ខ្វាយ
យកចិត្តទុកដាក់ រក្សាឪពុកម្តាយ ដូចរឿងបរិយាយ មកនេះឯងហោង។
មាតាបិតុ ឧបដ្ឋានគុណ អស់ពួកទុជ៌ន មាក់ងាយត្មះសង
តែពួកអ្នកប្រាជ្ញ អង់អាចច្បាស់ច្បង ប្រតិបត្តិឥតហ្មង ឆ្លងដល់ពោធិ ។

<u>ពន្យល់ពាក្យ</u>

ខ្ញុំព្រះករុណា អានថា "ខ្ញុំកូណា"ពាក្យនិយាយជាមួយព្រះសង្ឃ Ich

ជេតពន វត្តធំជាមជ្ឈមណ្ឌលរបស់ព្រះពុទ្ធ ទ្រង់គង់នៅចំនួន ១៩ឆ្នាំ Tempel

ឈរទ្រង់បាត្រ ព្រះសង្ឃឈរចាំញាតិញោមដាក់បាត្រលោក

Mönch geht, Essen zu suchen

ញោមស្រីប្រុស ពាក្យហៅ ម្តាយឪពុក របស់ព្រះសង្ឃ

| | |
|---|---|
| | Eltern des Mönchs |
| ដាស់តឿន | តឿនឲ្យភ្ញាក់រឭក, ឲ្យនឹកឃើញ Ein Typ geben |
| និមន្ត | ពាក្យប្រើជាមួយព្រះសង្ឃ |
| | ស្មើនឹងពាក្យថា ”ដើរ” gehen |
| បច្ចូសសម័យ | ពេលព្រឹកព្រហាម, ជិតភ្លឺ Früh-Morgen |
| បលិពោធ | សេចក្តីខ្វល់ខ្វាយ, ជាប់ជំពាក់ការងារ Hindernis |
| បុព្វចរិយា | ការប្រព្រឹត្តក្នុងកាលមុន, ចរិយា៣ របស់ព្រះពុទ្ធ |
| | was hat gemacht bevor |
| ពិសា | ហូប, ញ៉ាំ, ឆ្ងាញ់ពិសា essen |
| ពុទ្ធដីកា | ពាក្យរបស់ព្រះពុទ្ធ die Rede des Buddhas |
| មាតុបោសកសូត្រ | សំយុត្តនិកាយ បិដក ៣០ ទំព័រ ១៤០ |
| សលាក | ឆ្នោត die Karte |
| សាវត្ថី | ទីក្រុងបុរាណរបស់ឥណ្ឌា ព្រះពុទ្ធគង់នៅ |
| | ក្នុងក្រុងនេះ ២០ឆ្នាំ Sravasthi |

| | |
|---|---|
| សឹក | ឈប់នៅជាលោកតទៅទៀត<br>das Mönch-schwand verlassen |
| សៅហ្មង | អាប់អន់, មានមន្ទិល, ប្រឡាក់ schmutzig |
| អាគន្តុកភិក្ខុ | លោកដែលទើបនឹងនិមន្តមកដល់ថ្មី<br>der Mönch, der neue kommt |
| អាបត្តិបារាជិក | ទោសដ៏ធំក្នុងព្រះពុទ្ធសាសនា<br>ក្នុងចំណោមទោសទាំង ៧កង Vergehen |
| អាវុសោ | ពាក្យដែលព្រះសង្ឃហៅគ្នាទៅវិញទៅមក<br>das Wort, das der Mönch benutzt |
| អាសូរ | អាណិតទន់ចិត្ត, អាណិតជាប់ចិត្ត,<br>អាណិតខ្លោចចិត្ត Mitgefühl |
| ឥរិយាបថ | អាកប្បកិរិយា, ផ្លូវឬគន្លងនៃឥរិយា<br>ដំណើរ, ដេក, ឈរ, អង្គុយVerhalten |
| ឧបការៈ | ការទំនុកបម្រុង, ការផ្គត់ផ្គង់, ការផ្គុងផ្ដើម<br>Dankbarkeit |

# មាតុបោសកសូត្រ

យោ មាតរំ បិតរំ វា មច្ចោ ធម្មេន បោសេតិ

តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា

ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។

បុគ្គលណា ចិញ្ចឹមមាតាឬបិតាដោយធម៌ បណ្ឌិតទាំងឡាយ រមែងសរសើរបុគ្គលនោះ ក្នុងលោកនេះ ព្រោះការបម្រើមាតាបិតា ទាំងឡាយនោះ លុះបុគ្គលនោះ ទៅកាន់បរលោកហើយ រមែងរីករាយក្នុងឋានសួគ៌ ៕

សំយុត្តនិកាយ សគាថវគ្គ ទុតិយភាគ ៣០ ទំព័រ ១៤១

# រឿងដំរីចិញ្ចឹមម្ដាយ ៤

សត្ថា: កាលព្រះសាស្ដាគង់នៅនាវត្តជេតពន ទ្រង់បានសម្ដែងរឿងនេះឡើង ព្រោះប្រារព្ធភិក្ខុចិញ្ចឹមម្ដាយមួយអង្គ។ រឿងហ្នឹងមានដំណើរដូចគ្នានឹងរឿងព្រះសុវណ្ណសាមទ៉ុះឯង។ ព្រះសាស្ដាបានត្រាស់ហៅពួកភិក្ខុមកទូន្មានថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំនាំគ្នាពោល ទោសតិះដៀលភិក្ខុអង្គនោះឡើយ បោរាណកបណ្ឌិតទាំងឡាយ សូម្បីកើតក្នុងកំណើតសត្វតិរច្ឆាន ស៊ូអត់អាហារអស់ ៧ថ្ងៃ យំសម្រក់ទឹកភ្នែកព្រោះតែព្រាត់ម្ដាយ ទោះបីបានចំណីអាហារប្រៀបដោយក្រយ៉ាស្ងោយរបស់ស្ដេចក៏ដោយ ក៏មិនបរិភោគឡើយ ដរាបណាមិនបានជួបម្ដាយ។ ពួកភិក្ខុបានអារាធនា ទើបទ្រង់សម្ដែងអតីតនិទាននេះឡើង ដូចតទៅនេះ៖

អតីតេ ពារាណសិយំ: កាលពីព្រេងនាយ ព្រះបាទព្រហ្មទត្ត បានឡើងគ្រងរាជ្យនៅនាទីក្រុងពារាណសី រីឯព្រះបរមពោធិសត្វ បានកើតក្នុងកំណើតជាសត្វដំរីនាហិមវន្តប្រទេស ជាដំរីមានសម្បុរសសុទ្ធ មានរូបល្អគួរពិតពិលរមិលមើលជាទីពេញចិត្ត មានលក្ខណៈបរិបូណ៌ និងមានដំរី ៨ម៉ឺន ជាបរិវារ ។ ដំរីនោះ នៅចិញ្ចឹមរក្សាម្ដាយ (មេដំរី) ដែលចាស់ជរា ថែមទាំងខ្វាក់ភ្នែកទៀតផង។ ស្ដេចដំរី បានប្រគល់ទឹកឃ្មុំស្ករ ផ្លែឈើទុំខ្ចីផ្សេងៗ ដល់ពួកដំរីជាកូនចៅ

---

៤ ព្រះសុត្តន្តបិដក ខុទ្ទកនិកាយ ជាតក អដ្ឋមភាគ ៥៩ ទំព័រ ២១០

ដើម្បីយកទៅជូនម្ដាយពិសា។ តែពួកដំរីទាំងនោះ មិនបានជូនទៅម្ដាយស្ដេចដំរីពិសាទេ បែរជាយក បរិភោគដោយខ្លួនឯង។ (ក្រោយមក) ស្ដេចដំរីកាលឃ្លាំមើលក៏បានដឹងរឿងនោះ គិតថា អាត្មាអញនឹងចេញចោលហ្វូង ហើយចិញ្ចឹមម្ដាយដោយខ្លួនឯងវិញ! រួចហើយនៅវេលារាត្រីកាល ដែលពួកហ្វូងដំរីពុំបានដឹង ក៏លួចនាំម្ដាយរត់ទៅកាន់ជើងភ្នំចណ្ឌោរណៈ ស្នាក់នៅក្នុងគុហាភ្នំស្ថិតនៅក្បែរមាត់ស្រះឈូកមួយ ហើយតាំងចិញ្ចឹមម្ដាយតទៅ។

នាគ្រាមួយនោះ មានអ្នកថ្មើរព្រៃម្នាក់នៅក្រុងពារាណសី វង្វេងផ្លូវ រកកំណត់ទិសមិនបាន ក៏ស្រែកយំរៀបរាប់យ៉ាងទ្រហឹងរំពងព្រៃ។ ដំរីពោធិសត្វបានឮសម្រែកបុរសនោះ ក៏គិតថា "បុរសនេះ គ្មានទីពឹងទេ ឱ! ហាក់ដូចជាមិនសមគួរទាល់តែសោះ បើបណ្ដោយឲ្យបុរសនោះ ស្លាប់ក្នុងទីស្ថានដែលយើងរស់នៅយ៉ាងនេះ "រួចក៏ដើរសំដៅទៅបុរសនោះ។ គ្រាន់តែបានឃើញដំរី (មកពីចម្ងាយ) បុរសនោះភ័យរត់យ៉ាងលឿន តែស្ដេចដំរីក៏ស្រែកឃាត់សួរថា "នែ! បុរសកំសត់កុំរត់អី ខ្ញុំមិនធ្វើឲ្យអ្នកភ័យខ្លាចទេ! ចុះហេតុអ្វី បានជាអ្នកដើរទ្រហោយំពេញព្រៃអញ្ចឹង?" នាយថ្មើរព្រៃប្រាប់ថា "ហៃ! លោកជាធំ ខ្ញុំវង្វេងផ្លូវអស់៧ថ្ងៃនឹងថ្ងៃនេះហើយ"។ ស្ដេចដំរីក៏ពោលថា "បុរសដ៏ចម្រើន! ចូរ អ្នកកុំភ័យអី ខ្ញុំនឹងនាំអ្នកទៅដល់ផ្លូវមនុស្សណា៎ "រួចក៏ឲ្យបុរសនោះ ជិះលើខ្នង នាំចេញពីព្រៃទៅ។ បុរសនោះ ជាមនុស្សអាក្រក់ជួជាតិ បានកំណត់ដើមឈើ និង

ភ្នំជាសញ្ញាចេញទៅពារាណសីដោយគិតថា "អញនឹងទៅព្រះនគរ ប្រាប់ដល់ព្រះរាជា"។

កាលនោះ ដំរីមង្គលរបស់ព្រះរាជាក៏ស្លាប់ទៅ ទ្រង់បានឲ្យពួករាជ បុរសទូងស្គរប្រកាសថា "បើនរណាបានប្រទះឃើញមានដំរីល្អបរិបូណ៌ ដោយរូបអាចធ្វើជារាជទីនាំងបាន ចូរឲ្យដំណឹងភ្លាម"។ នាយថ្មើរព្រៃនោះក៏បានចូលទៅគាល់ព្រះរាជាទូលព្រះរាជឱង្ការថា "បពិត្រព្រះសម្មតិទេព! ទូលព្រះបង្គំបានឃើញស្ដេចដំរីសស្អាត មានសីលាចារ គួរជាព្រះទីនាំងរបស់ព្រះអង្គបានក្រាបទូល! សូមព្រះអង្គ ទ្រង់ត្រាស់បញ្ជាឲ្យនាយហ្មដំរីទៅជាមួយទូលព្រះបង្គំៗ នឹងបង្ហាញផ្លូវក្រាបទូល“។

ព្រះរាជាតបថា សាធុ (ប្រពៃហើយ) រួចបានបញ្ជូនហ្មដំរី និងបរិវារ ជាច្រើនទៅជាមួយដោយបញ្ជាថា "អ្នកទាំងឡាយ ចូរឲ្យបុរសនេះនាំ ផ្លូវទៅព្រៃចាប់ស្ដេចដំរីដ៏ប្រសើរដែលគាត់បានប្រាប់យើងមក“។ នាយ ថ្មើរព្រៃធ្វើដំណើរទៅជាមួយបរិវារ បានឃើញព្រះពោធិសត្វកំពុងចូល ទៅរកចំណីក្នុងស្រះឈូក។ ដំរីពោធិសត្វកាលឃើញហ្មដំរី ក៏គិតថា ភ័យនេះកើតឡើង មិនមែនដទៃណាក្រៅតែពីនាយថ្មើរព្រៃនោះទេ! អាត្មាអញជាសត្វមានកម្លាំងខ្លាំងអាចកំចាត់ហ្វូងដំរីទាំងពាន់ឲ្យវិនាសបាន! បើអញខឹងហើយ ក៏អាចនឹងព្រេចកំទេចនូវពលសេនា ព្រមទាំងអ្នកដែនទាំងអស់បាន! តែបើអាត្មាអញ ខឹងហើយ អញនឹងដាច់សីល (ព្រោះតែសម្លាប់មនុស្ស) ព្រោះហេតុនោះ ថ្ងៃនេះ

អញនឹងមិនខឹងជាដាច់ខាត ទោះជាគេចាក់ដោយលំពែងក៏ដោយចុះ!“ កាលស្តេចដំរីអធិដ្ឋានហើយ ក៏ឈរនៅស្ងៀមមិនសូម្បីងាកក្បាលបន្តិចសោះឡើយ ហ្មដំរីចុះទៅក្នុងស្រះឈូកមើលឃើញលក្ខណសម្បត្តិរបស់ស្តេចដំរីស្រដីថា "នែ! កូនប្រុស ឯងចូរមក" រួចក៏ចាប់ប្រមោយដែល ប្រៀបបាននឹងខ្សែប្រាក់ នាំបណ្តើរទៅអស់ ៧ថ្ងៃ ទើបបានដល់ក្រុងពារាណសី។

ថ្លែងអំពីមេដំរីជាម្តាយព្រះពោធិសត្វឯណោះវិញ កាលមិនឃើញកូនត្រឡប់មក ក៏សង្ស័យប្រាកដថា "កូនអញ ច្បាស់ជាត្រូវពួកស្តេច ឬ អាមាត្យជាដើមចាប់យកទៅហើយ តើដងព្រៃនេះនឹងរីកស្រស់ម្តេចបាន បើខ្ញុំព្រាត់កូនជាទីស្រឡាញ់ហើយនេះ?“ ក៏យំរៀបរាប់ភ្ជាប់ ដោយគាថាពីរបាទថា៖

ដើមពោនស្វាផង ដើមខ្លែងគង់ផង ដើមទទឹមនិងស្មៅធំឈ្មោះកររវរះ[៥] ផងក្រអៅឈូកនិងស្រងែផង ដុះទ្រុបទ្រុលហើយ ទាំងដើមកណ្ណិការ ជិតជើង ភ្នំក៏ចេញផ្កាដែរ ព្រោះតែដំរីនោះមិននៅ។

ក្នុងស្រុក ឬក្នុងក្រុងណាមួយ ព្រះរាជា ឬព្រះរាជកុមារណាមួយ មានគ្រឿងអាភរណៈជាវិការៈនៃមាស រមែងចិញ្ចឹមស្តេចដំរីដោយដុំនៃភោជន ដ្បិតដំរី

[៥] ស្មៅធំឈ្មោះកររវរះ បានដល់ ភិសៈ គឺ ក្រឱឈូក, មើមឈូក និងសាមកា គឺ ដើម ប្រយង្គុ, វល្លិប្រេងខ្លោ។ អដ្ឋកថា

ដែលព្រះរាជា ឬព្រះរាជកុមារ (គង់ហើយ) មិនតក់ស្លុត (ក្នុងសង្គ្រាម) អាចនឹងទម្លុះទម្លាយនូវក្រោះ (នៃពួកបច្ចាមិត្របាន)។

គ្រាន់តែបានពាក់កណ្ដាលផ្លូវ ហ្មដំរីក៏បានផ្ញើសារទៅថ្វាយព្រះរាជាៗ បានទ្រង់ព្រះសណ្ដាប់ហើយ ក៏ឲ្យគេរៀបចំតាក់តែងស្អិតស្អាងព្រះនគរ យ៉ាងស្អាត។ ហ្មដំរីបាននាំព្រះពោធិសត្វទៅកាន់រោងដំរី ដែលប្រដាប់ តាក់តែងដោយគ្រឿងអលង្ការអប់នឹងគ្រឿងក្រអូបផ្សេងៗ រៀបចំចង វាំងននយ៉ាងល្អប្រណិត ទើបទៅក្រាបទូលដល់ព្រះរាជា។ ព្រះរាជាបាន ត្រាស់បង្គាប់ឲ្យគេយកភោជនដ៏ប្រកបដោយរសជាតិផ្សេងៗ ទៅឲ្យព្រះពោធិសត្វ។ ស្ដេចដំរីមិនទទួលយកដុំបាយឡើយ ដោយតាំងចិត្តថា អាត្មាអញនឹងមិនបរិភោគទេ ព្រោះគ្មានម្ដាយ (នៅទីនេះ)។ គ្រានោះ ព្រះរាជាក៏អង្វរស្ដេចដំរីថា៖

ម្នាលដំរី អ្នកចូរទទួលពំនូតភោជនចុះ ម្នាលដំរី អ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយមានច្រើន អ្នកនឹងធ្វើនូវរាជកិច្ចទាំងនោះ។

ព្រះពោធិសត្វឮហើយ ក៏តបវិញថា៖

មេដំរីនោះជាសត្វកំព្រា (យំព្រោះព្រាត់កូន) ខ្វាក់ភ្នែក មិនមានគេដឹក នាំទង្គិចជើងនឹងជង្គត់ឈើ ហើយបែរមុខទៅរកភ្នំចណ្ឌោរណៈដួលនៅ។

ភ្លាមនោះ ព្រះរាជាក៏ត្រាស់សួរទៅទៀតថា៖

ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែកមិនមានគេដឹកនាំ ទង្គិចជើងនឹង ដង្គត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង?

ព្រះពោធិសត្វតបថា៖

បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងដង្គត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ ត្រូវជាមាតារបស់ទូលបង្គំជាខ្ញុំ។ បពិត្រមហារាជ ខ្ញុំចិញ្ចឹមនូវមេដំរីខ្វាក់មួយ បើអត់ពីខ្ញុំទៅ ម្តាយខ្ញុំនឹងស្លាប់មិនខាន តែអត់ពីម្តាយហើយ តើប្រយោជន៏អ្វីទៅ ដោយគ្រឿងឥស្សរិយៈទាំងនេះ ម្តាយខ្ញុំអត់អាហារ ៧ថ្ងៃហើយ ព្រោះហេតុនោះ សូមទ្រង់ដោះលែងទូលព្រះបង្គំជាខ្ញុំ ឲ្យបានជួបម្តាយផង

ព្រះរាជាបានទ្រង់ព្រះសណ្តាប់យ៉ាងនោះហើយ កាលទ្រង់បង្គាប់ឲ្យ គេដោះលែងទើបត្រាស់ថា៖

អ្នកទាំងឡាយចូរលែងនូវដំរីដ៏ប្រសើរនុ៎ះ ជាសត្វចិញ្ចឹមនូវមាតា ចូរ ឲ្យដំរីបានជួបនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ។

បានឮថា ដំរីនោះ គ្រាន់តែបានរួចចាកចំណងភ្លាម ក៏សម្រាកបន្តិច បានសម្តែងទសពិធរាជធម៌ថ្វាយដល់ព្រះរាជា ប្រទានឱវាទថា „បពិត្រ មហារាជព្រះអង្គ ចូរជាបុគ្គលកុំប្រមាទ“ រួចហើយក៏ចេញចាកព្រះនគរ ទាំងដែលមហា

ជនកំពុងបូជាដោយគ្រឿងក្រអូបផ្សេងៗ សំដៅ ទៅដល់ស្រះឈូកក្នុងថ្ងៃនោះឯង។ គិតថា នឹងឲ្យអ្នកមេបានបរិភោគដោយផ្ទាល់ដៃខ្លួន ក៏ដកយកក្រអៅឈូកនិងមើមឈូកជាច្រើន ព្រមទាំងដងទឹកដោយប្រមោយ ចេញអំពីទីសម្រាកសម្ងំដើរសំដៅទៅរកម្ដាយ ដែលកំពុងក្រាបដេកនាមាត់ទ្វារល្អាង ស្រោចស្របទឹកទៅលើកាយ ម្ដាយដែលអត់អាហារ ៧ថ្ងៃហើយ ឲ្យមានកម្លាំងឡើង។ ព្រោះដូច្នោះ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវអភិសម្ពុទ្ធគាថា ដើម្បីបញ្ជាក់សេចក្ដីនោះថា៖

ដំរីគ្រាន់តែរួចចាកចំណង ដែលព្រះរាជាកាសីបានបញ្ជូនទៅ សម្រាក ខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ដំរីនោះចេញទៅអំពីភ្នំនោះ ដើរ ទៅកាន់ព្រៃជាទីពួនសម្ងំដ៏ត្រជាក់ ដែលដំរីធ្លាប់សេព (នៅ) ហើយដង ទឹកដោយប្រមោយយកមកស្រោចស្រពមាតា។

មេដំរីនៃពោធិសត្វសម្គាល់ថា ភ្លៀងធ្លាក់ ក៏ស្ដីបន្ទោសថា៖

ភ្លៀងអ្វីហ្នឹងផ្ដេសផ្ដាស បង្អុរចុះពុំជួកាលសោះ កូនបង្កើតរបស់អញ ដែលជាអ្នកបម្រើអញទៅបាត់ហើយតើ!

ដើម្បីលួងលោមម្ដាយព្រះពោធិសត្វក៏ពោលពេលនោះថា៖

បពិត្រអ្នកមេ សូមអ្នកក្រោកឡើង សម្រាន្តអ្វី ខ្ញុំជាកូនបង្កើតរបស់លោក ដែលព្រះរាជាកាសីទ្រង់ប្រកបដោយប្រាជ្ញាមានយសបានលែង មកវិញហើយ ឥឡូវនេះ កូនបាននាំភោជនមកហើយ សូមអ្នកមេក្រោកឡើង ពិសានូវភោជន នេះចុះ។

មេដំរីមានចិត្តត្រេកអរពន់ពេក កាលថ្វាយព្រះពរដល់ព្រះរាជា ក៏បានពោល គាថាចុងក្រោយថា៖

ព្រះរាជាណា បានលែងកូនរបស់ខ្ញុំ ជាអ្នកកោតក្រែងចំពោះបុគ្គលចាស់ សព្វៗកាល សូមព្រះរាជានោះ ញុំាងដែនរបស់ពួកអ្នកកាសីឲ្យចម្រើន គង់ព្រះ ជន្មនៅអស់កាលយូរអង្វែងចុះ។

ក្នុងកាលនោះព្រះរាជាជ្រះថ្លាក្នុងគុណរបស់ព្រះពោធិសត្វ បានសាង ភូមិ មួយនៅក្បែរស្រះឈូក ទំនុកបម្រុងព្រះពោធិសត្វនិងមេជានិច្ច ។ ចំណេរ កាលខាងក្រោយមក កាលមេដំរីស្លាប់ហើយ ស្តេចដំរីក៏បានធ្វើ ការរក្សាទុក យ៉ាងស្រួលបួលហើយដែរ ទើបទៅកាន់អាស្រមបទមួយ ឈ្មោះករណ្ឌកៈ ធ្វើ វត្តប្រតិបត្តិចំពោះពួកឥសី ៥០០អង្គ ដែលគង់នៅទីនោះ ជាស្ថានចុះអំពីព្រៃ ហេមពាន្តមក។

រីឯព្រះរាជា បានយកថ្មឆ្លាក់រូបដំរីព្រះពោធិសត្វ ធ្វើសក្ការបូជា មិនតែប៉ុណ្ណោះ ពួកជនដែលរស់នៅទូទាំងប្រទេសឥណ្ឌា[៦] បានប្រជុំគ្នាធ្វើ បុណ្យមួយឈ្មោះថា ហត្ថិមហោ ជារៀងរាល់ឆ្នាំរហូតដល់សព្វថ្ងៃ។

ព្រះសាស្ដាទ្រង់បាននាំរឿងនេះមក ហើយទ្រង់ប្រកាសសច្ចធម៌ សជាតក៏។ កាលចប់សច្ចធម៌ មាតុបោសកភិក្ខុ ក៏បានលុះសោតាបត្តិផល ព្រះរាជាក្នុងកាលនោះ បានមកជាព្រះអានន្ទ, នាយថ្មើរព្រៃជួជាតិ បានមកជាទេវទត្ត, ហ្មដំរីជាព្រះសារីបុត្រ, មេដំរីជាព្រះនាងមហាមាយា រីឯស្ដេចដំរីដែលចិញ្ចឹមម្ដាយ គឺព្រះតថាគតនេះឯងហោង។

រឿងដំរីចិញ្ចឹមម្ដាយចប់ ៕

## អវសានកាព្យ

ដំរីពោធិសត្វ ផុតពីមុខងារ ដែលព្រះរាជា ទ្រង់ប៉ងចំពោះ
ក៏ព្រោះតែគុណ គឺការសន្ដោស ចិញ្ចឹមម្ដាយស្មោះ អស់ភ័យអន្ដរាយ។
មិនត្រឹមប៉ុណ្ណោះ ឈ្មោះល្បីរន្ទឺ អ្នកស្រុកជំនឿ ជឿជាក់ភក្ដី

---

[៦] មិនមែនតែប្រទេសឥណ្ឌាមួយទេ ដែលនៅធ្វើបុណ្យនេះរាល់ៗឆ្នាំ សូម្បី ប្រទេសស្រីលង្កា និងប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាមួយចំនួនទៀត ដូចជាមន និងខ្មែរសុរិន្ទយើងមានពិធីបុណ្យនេះដែរ តែប្រហែលជាសំដៅន័យផ្សេងគ្នា ។

គោរពបូជា មង្គលដំរី រហូតសព្វថ្ងៃ មិនសាបសូន្យឡើយ ។
នេះហើយគឺគុណបុណ្យបម្រើម្ដាយ ទោះជារូបកាយ រលាយទៅហើយ
តែពពួកជន នៅជំនាន់ក្រោយ ពិតមិនកន្ដើយ បូជាសរសើរ ។
រំពូកនឹកដល់ អង្គព្រះកុញ្ជរ ប្រសើរបវរ ល្អសព្វអន្លើ
បូជាគោរព សូមភប់ចំទើរ ទៅលើអំពើ ដើរដូចព្រះអង្គ ។

## ពន្យល់ពាក្យ

| | |
|---|---|
| កុញ្ជរ | សត្វដំរី |
| ក្រាបទូល | កន្ទុយពាក្យសម្រាប់ប្រើជាមួយស្ដេច |
| ក្រយាស្ងោយ | អាហារបរិភោគរបស់ព្រះរាជា |
| គាល់ព្រះរាជា | ចូលទៅជួបនឹងស្ដេច |
| គុហាភ្នំ | រូងភ្នំ ឬល្អាងភ្នំ |
| គ្រឿងឥស្សរិយៈ | គ្រឿងស័ក្កយស និងអំណាចផ្សេងៗ |
| ជួជាតិ | ដែលមានជាតិទន់ទាប, ថោកថយ |

| | |
|---|---|
| ដង្គត់ឈើ | គល់ឈើសល់ពីគេកាប់កាត់ |
| ថ្មើរព្រៃ | អ្នកដើរព្រៃ ឬព្រានព្រៃ |
| ទង្គិចជើង | ដើរជាន់ ឬប៉ះជំពប់ |
| ទូលព្រះរាជឱង្ការ | ប្រាប់ដំណឹងដល់ស្តេច |
| នគរ | ទីក្រុង |
| បរិវារ | អ្នកហែហម, គ្នីគ្នា គូកន, កូនចៅ |
| បោរាណកបណ្ឌិត | អ្នកប្រាជ្ញពីមុនៗ មក |
| ពលសេនា | កងទ័ព, ពួកទាហាន |
| ពំនូតភោជន | ដុំបាយ |
| ព្រះសម្មតិទេព | បុគ្គលដែលសន្មតស្មើនឹងទេវតា, ស្តេច |
| រាជកិច្ច | ការងាររបស់ស្តេច |
| រាជទីនាំង | យានជំនិះរបស់ស្តេច |
| វេលារាត្រីកាល | ពេលយប់ស្ងាត់, យប់អាធ្រាត |

| | |
|---|---|
| សម្បុរ | ពណ៌ |
| សារ | សំបុត្រ |
| សីលាចារ | មានឫកពារល្អ |
| ហត្ថមហោ | បុណ្យដំរី |
| ហ្មដំរី | អ្នកចាប់ ឬបង្ហាត់ដំរី |
| ហិមវន្តប្រទេស | តំបន់ព្រៃហេមពាន្ត, ព្រៃទឹកសន្សើម |
| អតីតនិទាន | រឿងដែលមានរួចហើយ |
| អធិដ្ឋាន | ការតាំងចិត្ត, អត់ធ្មត់ |
| អ្នកដែន | អ្នកស្រុក, អ្នកនគរទាំងមូល |
| អារាធនា | អញ្ជើញ, ស្នើសុំ |




មណ្ឌលវប្បធម៌ខ្មែរនៅស្វីស Khmer Kulturzentrum in der Sweiz

Kirchgasse 12

5746 Walterwil So